| ឯកសារតម្រូវការចុះបញ្ជីលើកដំបូងមានលក្ខណៈដាច់ដោយដុំ និងចេញប័ណ្ណ | | |
|---|---|---|
| ល.រ | ឯកសារតម្រូវ | ចំនួន (ច្បាប់) |
| 1 | ពាក្យសុំចុះបញ្ជីដី (ច្បាប់ដើម) | 02 |
| 2 | ឯកសារបញ្ជាក់អត្តសញ្ញាណក្បាលដី ជាអាទិ៍លេខក្បាលដីទីតាំងភូមិសាស្ត្រផែនទីបង្ហាញទីតាំងក្បាលដី ឬ ឯកសារពិពណ៌នាអំពី ទីតាំងក្បាលដីព្រំប្រទល់ក្បាលដីទំហំដីរូបភាពនៃការប្រើប្រាស់ដី ឬឯកសារគតិយុត្តផ្សេងទៀតដែលនៅមានអានុភាព (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 3 | ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់ដី ឬអ្នកកាន់កាប់ដី ÷<br>អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ (បើជារូបវន្ដបុគ្គល) លក្ខន្តិកៈ និងឯកសារបញ្ជាក់ការចុះបញ្ជីនីតិបុគ្គល(បើជានីតិបុគ្គល) ឬឯកសារផ្សេងទៀត (ច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម លើកលែងតែសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ដែលត្រូវយកច្បាប់ដើម) | 03 |
| 4 | ឯកសារបញ្ជាក់ប្រភព និងកាលបរិច្ឆេទនៃការទទួលបានដី ជាអាទិ៍ លិខិតប្រគល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច កិច្ចសន្យា (លក់ទិញ ឬប្រទានកម្ម ឬដូរ ឬលិខិតផ្ទេរសិទ្ធិកាន់កាប់) សន្តតិកម្ម(សេចក្តីចម្លងសំបុត្រមរណភាព ឬសេចក្តីចម្លងសំបុត្របញ្ជាក់មរណភាពរបស់មតកជន សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សន្តតិជន សំបុត្រតំណវង្សត្រកូល សេចក្តីចម្លងសំបុត្រអាពាហ៍ ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ បើជាសហព័ទ្ធរបស់មតកជន ឯកសារបញ្ជាក់សមត្ថភាព របស់សន្តតិជនក្នុងការទទួលមរតក ដែលចេញដោយតុលាការ ព្រមទាំងកិច្ចព្រមព្រៀងបែងចែកមរតក មតកសាសន៍ (ប្រសិនបើមាន) សេចក្តីសម្រេចរបស់តុលាការ (សាលក្រម ឬសាលដីកា ឬដីកាសម្រេចស្ថាពរ ឬកំណត់ហេតុសះជា ឬកំណត់ហេតុទទួលស្គាល់ នូវការទាមទារ) ឬឯកសារផ្សេងទៀត (ច្បាប់ដើម ឬច្បាប់ចម្លង ដែលបានធ្វើនីត្យានុកូលកម្ម លើកលែងតែកិច្ចសន្យា សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានត្រូវ យកច្បាប់ដើម ០១ច្បាប់ ជាចាំបាច់) | 03 |

| | | |
|---|---|---|
| 5 | ឯកសារបញ្ជាក់សិទ្ធិផ្សេងៗលើក្បាលដី ÷ ឯកសិទ្ធិ ឬការបញ្ចាំ ឬហ៊ីប៉ូតែក ឬសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ឬសេវភាព (ប្រសិនបើមាន) (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លង ដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 6 | ឯកសារបញ្ជាក់ប្រភេទទ្រព្យសម្បត្តិរបស់បុគ្គលមានសិទ្ធិចុះបញ្ជី ដែលជារូបវន្តបុគ្គល ÷<br>- បើជាទ្រព្យរួមប្តីប្រពន្ធត្រូវមានជាអាទិ៍ ÷ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (ប្រសិនបើមាន) ឯកសារបញ្ជាក់ ការទទួលបានទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ (លើកលែងតែទ្រព្យដែលសហព័ន្ធ ទទួលបានដោយប្រទានកម្ម ឬសន្តតិកម្ម ឬអច្ច័យទាន ឬទ្រព្យជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យដោយឡែក)<br>- បើជាទ្រព្យដោយឡែក ត្រូវមានជាអាទិ៍ ÷ ឯកសារបញ្ជាក់អំពី ស្ថានភាពស៊ីវិល (សេចក្តីចម្លង សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឬលិខិតបញ្ជាក់លីវ ឬមេម៉ាយ ឬពោះម៉ាយ ឬសេចក្តីសម្រេចរបស់តុលាការអំពីអវត្ដមាន ឬការបាត់ខ្លួនរបស់សហព័ន្ធម្ខាងទៀត) កិច្ចសន្យាទ្រព្យសម្បត្តិ ប្តី-ប្រពន្ធ (ប្រសិនបើមាន) ឯកសារបញ្ជាក់ការទទួលបានទ្រព្យនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទទួលបានដោយប្រទានកម្ម ឬសន្តតិកម្ម ឬអច្ច័យទាន ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែក ឬបន្ថែមការបញ្ជាក់ របស់សហព័ន្ធម្ខាងទៀត<br>- ឯកសារបញ្ជាក់អំពីចំណែករបស់ម្ចាស់សិទ្ធិម្នាក់ៗ (ប្រសិនបើមាន) (បើជាទ្រព្យកម្មសិទ្ធិអវិភាគ ឬ ទ្រព្យសហភោគី) ឯកសារបញ្ជាក់អំពីចំណែកឯកជននិងចំណែករួម(បើជាទ្រព្យសហកម្មសិទ្ធិ) (ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |
| 7 | កិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ក្នុងករណីទ្រព្យអវិភាគ ហើយពាក្យសុំចុះបញ្ជីអំពីកិច្ចសន្យា ហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគ ត្រូវបានធ្វើឡើងព្រមគ្នាជាមួយពាក្យសុំចុះបញ្ជីដី (ច្បាប់ដើម០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 8 | ឯកសារបញ្ជាក់សិទ្ធិតំណាងរបស់អភិបាលតំណាងឱ្យនីតិបុគ្គល ក្នុងករណី អ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល(ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |

| | | |
|---|---|---|
| 9 | ឯកសារបញ្ជាក់សិទ្ធិតំណាង ក្នុងករណីអ្នកដាក់ពាក្យសុំចុះបញ្ជីជាជនស្ថិតក្រោមអ្នកតំណាង ដែលកំណត់ដោយច្បាប់ | 03 |
| 10 | ឯកសារប្រគល់សិទ្ធិតំណាង ក្នុងករណីពាក្យសុំចុះបញ្ជី ធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ (ច្បាប់ដើម ០១ច្បាប់ និងច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម ០២ច្បាប់) | 03 |
| 11 | ប័ណ្ណចាស់ ប្រសិនបើមាន (ច្បាប់ដើម) | 03 |
| 12 | ឯកសារពាក់ព័ន្ធផ្សេងទៀត ក្នុងករណីចាំបាច់ ÷ ......................................<br>(ច្បាប់ដើម ឬច្បាប់ចម្លងដែលបានធ្វើនីត្យានុកូលកម្ម) | 03 |